**សុន្ទរកថាស្វាគមន៍**

**របស់ឯកឧត្តម ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ក្នុងពិធីបើកសន្និបាតបូកសរុបការងារឆ្នាំ ២០១៣**

**និងទិសដៅការងារឆ្នាំ ២០១៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ**

**នៅសាលសន្និសីទចតុមុខ**

**ថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤**

- **សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
- **ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិការាជរដ្ឋាភិបាល**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន**
- **លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ**
- **សមាជិក សមាជិកាសន្និបាត ជាទីមេត្រី**

ថ្ងៃនេះ គឺជាឱកាសដ៏សំខាន់មួយ ដែលក្រសួងអភិវឌ្ឍន៍ជនបទ ប្រារព្ធសន្និបាតបូកសរុបការងារឆ្នាំ ២០១៣ និងទិសដៅការងារឆ្នាំ ២០១៤ លើកទី ១ របស់ខ្លួន សម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា។ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលបានអញ្ជើញជាអធិបតីក្នុងពិធីបើកសន្និបាតនាពេលនេះ ។ ខ្ញុំសូមថ្លែងនូវការស្វាគមន៍ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ តំណាងក្រសួង ស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល តំណាងអាជ្ញាធរដែនដីរាជធានី-ខេត្ត ដែលមានវត្តមានក្នុងឱកាសនេះ។

តាមទម្លាប់នៃការអនុវត្តកន្លងមក នៅពេលដែលឆ្នាំចាស់បានបញ្ចប់ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ តែងត្រូវបានរៀបចំឡើង និងបានប្រើប្រាស់ជាវេទិកាសម្រាប់គូសរំលេចអំពីសមិទ្ធផលធំៗដែលសម្រេចបាន អំពីទិសដៅអាទិភាព និងអំពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់ក្រសួងអភិវឌ្ឍន៍ជន

បទ ក្នុងការឈានទៅសម្រេចឲ្យបានជោគជ័យនូវទិសដៅអាទិភាពទាំងអស់នោះ ដើម្បីបម្រើនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិមាតុភូមិ និងឆ្លើយតបទៅនឹងសំណូមពរ និងសេចក្តីត្រូវការទាំងឡាយរបស់ប្រជាជន។

សន្និបាតរបស់យើងនៅពេលនេះ ប្រព្រឹត្តទៅក្នុងបរិការណ៍មួយដែលសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកមានភាពមិនប្រាកដប្រជា ប៉ុន្តែកម្ពុជាអាចធានារក្សាបានយ៉ាងគត់មត់នូវស្ថិរភាពវិស័យហិរញ្ញវត្ថុ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពសង្គម ជាពិសេសលំនឹងជីវភាពរស់នៅរបស់ប្រជាជនទាំងមូល ទោះបីជាព្រះរាជាណាចក្រកម្ពុជាយើងត្រូវជួបប្រទះនឹងគ្រោះធម្មជាតិ បណ្តាលមកពីទឹកជំនន់ក្នុងឆ្នាំ ២០១៣ នេះក្តី។ បរិការណ៍នេះ មិនមែនកើតឡើងដោយឯកឯង ឬចៃដន្យទេ ប៉ុន្តែគឺកើតចេញពីអគ្គមគ្គុទ្ទេសក៍ដឹកនាំរដ្ឋប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃ ប្រាកដនិយម និងបញ្ញាញាណដ៏ភ្លឺស្វាងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាពិសេស នៅក្នុងការដឹកនាំយុទ្ធនាការទប់ទល់ និងដោះស្រាយផលប៉ះពាល់បណ្តាលមកពីទឹកជំនន់ដែលជាគ្រោះធម្មជាតិដ៏ធ្ងន់ធ្ងរមកលើប្រជាជន និងសេដ្ឋកិច្ចជាតិកាលពីពេលថ្មីៗនេះ ។ ការដាក់ចេញវិធានការដោះស្រាយទឹកជំនន់ដ៏ទាន់ពេលវេលា និងមានប្រសិទ្ធភាព មិនត្រឹមតែធានាបាននូវប្រក្រតីភាពនៃជីវភាពរស់នៅរបស់ប្រជាជនទូទាំងប្រទេស ពិសេសប្រជាជននៅជនបទក្នុងពេលទឹកជំនន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅតែអាចធានារក្សាបាននូវចលនាការនៃកំណើនសេដ្ឋកិច្ចដដែល ។ ក្នុងស្មារតីនេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំជំនះនូវរាល់ឧបសគ្គគ្រប់បែបយ៉ាងក្នុងការអនុវត្តនូវទិសដៅ និងភារកិច្ចរបស់ខ្លួន ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនដូចជា *អភិបាលកិច្ចល្អ ការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកាប្រចាំឆ្នាំ ការប្រើប្រាស់ជំនួយហិរញ្ញប្បទានសហប្រតិបត្តិការលើវិស័យអភិវឌ្ឍន៍ជនបទ ការកសាង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ការផ្គត់ផ្គង់ទឹកជនបទ និងថែទាំសុខភាពជនបទ ការងារអភិវឌ្ឍសហគមន៍ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ការងារអភិវឌ្ឍសេដ្ឋកិច្ចជនបទ វិស័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងការអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ។*

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជាទីគោរព**
- **អង្គសន្និបាតទាំងមូល ជាទីមេត្រី**

◆ពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ ក្រសួងសម្រេចបានជោគជ័យកំណែទម្រង់រដ្ឋបាល ដោយបានធ្វើជំរឿនមន្ត្រីរាជការ ទាំងនៅថ្នាក់កណ្តាល និងមន្ទីរអភិវឌ្ឍន៍ជនបទទាំង ២៤ រាជធានី ខេត្ត។ ឆ្នាំ២០១២ មន្ត្រីរាជការក្រប ខ័ណ្ឌមានចំនួន ១ ៨០៣ នាក់ បច្ចុប្បន្នមានក្របខ័ណ្ឌសរុបចំនួន ១ ៧៧៩ នាក់ ។

ក្រសួងបានដាក់មន្ត្រីរាជការឲ្យចូលនិវត្តន៍ ៣៨ នាក់ លុបឈ្មោះ ១៩ នាក់ ផ្ទេរក្របខ័ណ្ឌចេញ ០៦នាក់ រើសមន្ត្រីក្របខ័ណ្ឌថ្មីចំនួន ៣៨ នាក់ និងផ្ទេរក្របខ័ណ្ឌមកក្រសួងចំនួន ០១ នាក់ ។

♦ការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកាប្រចាំឆ្នាំ ÷

នៅឆ្នាំ ២០១៣ នេះ ក្រសួងទទួលបានថវិកាសរុបចំនួន ១៧៧.៩៧២.៥០០.០០០ រៀល ។

♦ឆ្នាំ ២០១៣ នេះ ក្រសួងអភិវឌ្ឍន៍ជនបទ បាន និងកំពុងបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តគម្រោងសំខាន់ៗមួយចំនួន ។ ដៃគូអភិវឌ្ឍន៍ទាំងនោះរួមមាន អង្គការ (UNICEF) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិអភិវឌ្ឍន៍ណ័រឌីក (NDF) ធនាគាររបស់សាធារណរដ្ឋកូរ៉េ (KEXIM BANK) ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KFW) កម្មវិធីស្បៀងអាហារពិភពលោក (WFP) ធនាគារពិភពលោក (WB) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AUSAID) និងវិទ្យាស្ថានសេដ្ឋកិច្ចជនបទកូរ៉េ (KREI) ។ គម្រោងទាំងនោះរួមមាន÷

**១.** កម្មវិធីទឹកស្អាត និងអនាម័យ ក្រោមហិរញ្ញប្បទានរបស់អង្គការ UNICEF ដែលមានគោលដៅលើកស្ទួយសុខមាលភាពប្រជាជននៅតាមតំបន់ជនបទនៃខេត្តចំនួន ១០ ។

**២.** គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យជំហានទី ២ សម្រាប់អនុវត្ត រយៈពេល ៥ ឆ្នាំ (២០១០-២០១៥) ក្នុងខេត្តគោលដៅចំនួន ៦ ។

**៣.** គម្រោងកែលម្អផ្លូវជនបទរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សាធារណរដ្ឋកូរ៉េ និងមូលនិធិអភិវឌ្ឍន៍ណ័រឌីក សម្រាប់ធ្វើការកែលម្អផ្លូវជនបទពីក្រាលក្រួសក្រហម ប្រវែង ៥០៣,៩ គ.ម ទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ប្រភេទ (DBST) នៅខេត្តគោលដៅចំនួន ៧ ។

**៤.** កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេល ៣ ឆ្នាំ ពីឆ្នាំ ២០១១-២០១៤ ។

**៥.** គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហាន ២ (RIP-II) និងគម្រោងសង្គ្រោះបន្ទាន់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ (FRRI) ក្រោមជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ សម្រាប់អនុវត្តរយៈពេល ០៣ ឆ្នាំ នៅក្នុងខេត្តចំនួន ០៧ ។

**៦.** កម្មវិធីស្បៀងអាហារពិភពលោក (WFP) ប្រើប្រាស់ស្បៀងពលកម្មអនុវត្តលើខេត្តគោលដៅចំនួន ០៦។

**៧.** គម្រោងស្តារឡើងវិញជាបន្ទាន់ នូវហេដ្ឋារចនាសម្ព័ន្ធដែលរងខូចខាតដោយខ្យល់ព្យុះកេតសាណា (KERRP) សម្រាប់កសាង និងស្តារឡើងវិញផ្លូវជនបទ កសាងអណ្តូងទឹក និងបង្គន់គ្រួសារ ក្នុង

ខេត្តគោលដៅចំនួន ៦ ។

**៨.** គម្រោងឥណទានខ្នាតតូច គាំទ្រដោយវិទ្យាស្ថានសេដ្ឋកិច្ចជនបទកូរ៉េ (KREI) បានផ្តល់ថវិកាដល់ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន **៨៦.៥០៤,៦៨** ដុល្លារអាមេរិក នៅឆ្នាំ ២០០៩ ។ នៅឆ្នាំ ២០១៣ ថវិការបស់គម្រោងឡើងដល់ **១៤៨.០២៣,៤៩** ដុល្លារ ដោយមានអ្នកខ្ចី ២៧៧ នាក់ នៅក្នុងភូមិគោលដៅចំនួន ០៨ ស្ថិតក្នុងស្រុកក្រូចឆ្មារ ព្រៃឈរ និងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

**៩.** គម្រោងស្តារឡើងវិញបន្ទាន់ នូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តខូចខាតដោយគ្រោះទឹកជំនន់ឆ្នាំ ២០១១ (FDERP) ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង AUSAID ដែលមានទឹកប្រាក់សរុប ១៩,០៥ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់ជួសជុលឡើងវិញផ្លូវជនបទចំនួន ៣៨ ខ្សែ ដែលមានប្រវែងសរុប ៤៤៩,៩ គ.ម នៅក្នុងខេត្តគោលដៅចំនួន ៥ ។

**១០.** គម្រោងអភិវឌ្ឍន៍ជនបទដីទំនាបបឹងទន្លេសាប (Tonle Sap Lowlands Rural Development Project) ក្រោមហិរញ្ញប្បទានឥណទាន និងជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់កែលម្អជីវភាពរស់នៅរបស់ប្រជាជនក្នុងខេត្តចំនួន ៣ ។

◆ យើងបានខិតខំជំរុញការងារអភិវឌ្ឍសហគមន៍ ដោយបានជីកស្រះតាមគ្រួសារ ផ្តល់ពូជបន្លែចម្រុះ ផ្តល់ពូជត្រី មេគោ កូនជ្រូក ពូជមាន់ និងកូនឈើហូបផ្លែ ដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារកែលម្អជីវភាពរស់នៅ។ ទន្ទឹមនេះ យើងបានបណ្តុះបណ្តាលគ្រូបង្គោលអំពីសញ្ញាណសន្តិសុខស្បៀង ដើម្បីជួយណែនាំប្រជាជនអំពីរបៀបធ្វើជីកំប៉ុស្តសម្រាប់ដាំដំណាំក្នុងគ្រួសារ។

◆ ក្នុងការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស យើងក៏បានបណ្តុះបណ្តាលធនធានមនុស្សជាច្រើននៅក្នុងប្រទេស និងបញ្ជូនមន្ត្រីទៅក្រៅប្រទេស ទស្សនកិច្ចសិក្សា និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញនានាសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងយុវជនឥតការងារធ្វើ។

◆ កម្មវិធីឥណទានសហប្រតិបត្តិការជាមួយដៃគូ បានផ្តល់ឥណទានសរុបចំនួន **៦១៣៧.២៤៥.២០០** រៀល ស្មើនឹង **១.៥៣២.៨១១,៣០** ដុល្លារ មានគ្រួសារខ្ចីចំនួន **៨.៧២៣** គ្រួសារ នៅភូមិគោលដៅចំនួន ២៨០ ឃុំចំនួន ៩៦ និងស្រុកចំនួន ២៩ នៅខេត្តកំពង់ចាម ពោធិ៍សាត់ កំពត សៀមរាប កោះកុង បាត់ដំបង តាកែវ ស្វាយរៀង និងខេត្តបន្ទាយមានជ័យ។

◆ ការងារជនជាតិភាគតិច បានចេញលិខិតប្រកាសទទួលស្គាល់ជាផ្លូវការនូវសហគមន៍ជនជាតិដើមភាគតិចចំនួន ១៩ សហគមន៍ នៅខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង និងខេត្តបាត់ដំបង និងបានបញ្ចប់ការសិក្សាស្រាវជ្រាវរួចរាល់ចំនួន ១១ សហគមន៍ លើផែនការសរុប ៣០ សហគមន៍ ដែលបានវាយតម្លៃលក្ខណៈវិនិច្ឆ័យកំណត់អត្តសញ្ញាណ ។

•គណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំអនុវត្តគម្រោងអភិវឌ្ឍន៍ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំសាងសង់ផ្ទះ និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសំខាន់ៗជាច្រើន សម្រួលដល់ជីវភាពរស់នៅរបស់គ្រួសារយោធិន។ លទ្ធផលសម្រេចបានមានដូចខាងក្រោម÷

**ក. ខេត្តឧត្តរមានជ័យ**

- សាងសង់ផ្ទះជំហានទី ១ សរុបបានចំនួន ១ ១០០ ខ្នង
- សាងសង់ផ្លូវបាន ០១ ខ្សែ ប្រវែង ១ ៦០០ ម ស្ថិតក្នុងភូមិសំរោងសែនជ័យ ១
- សាងសង់មណ្ឌលសុខភាពចំនួន ០៦ កន្លែង និងសាងសង់សាលារៀនចំនួន ០២ ខ្នង

**ខ-ខេត្តព្រះវិហារ**

-ការងារសាងសង់ផ្ទះជំហានទី ២ សរុបចំនួន ៩៨៣ ខ្នង។

ជោគជ័យធំៗទាំងនេះគឺសុទ្ធតែបានមកពីការចង្អុលបង្ហាញដោយផ្ទាល់ប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងរយៈពេលកន្លងមក និងការគាំទ្រពីសំណាក់ថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ ដៃគូអភិវឌ្ឍន៍នានា អាជ្ញាធរដែនដី និងប្រជាពលរដ្ឋគ្រប់មូលដ្ឋាន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ជាមួយនឹងក្តីសប្បាយរីករាយ ចំពោះសមិទ្ធផលដែលយើងសម្រេចបានក្នុងឆ្នាំ ២០១៣ ក៏បានបន្សល់ទុកឲ្យយើងនូវបញ្ហាប្រឈម ដែលយើងត្រូវចាត់វិធានការអនុវត្តបន្តឲ្យបានជោគជ័យក្នុងឆ្នាំថ្មី ឆ្នាំ ២០១៤ នេះ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សូមមានសិរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ និងជោគជ័យគ្រប់ភារកិច្ចក្នុងឆ្នាំថ្មី ឆ្នាំ ២០១៤។

សូមជូនពរឲ្យដំណើរការរបស់សន្និបាតប្រព្រឹត្តទៅទទួលបានផ្លែផ្កា និងជោគជ័យល្អប្រសើរ ។

ដើម្បីផ្តល់ជូនអង្គសន្និបាតនូវគោលការណ៍ និងយុទ្ធសាស្ត្រជាគន្លឹះថ្មីៗទៀត ខ្ញុំសូមគោរពអញ្ជើញ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ថ្លែងសុន្ទរកថាបើកសន្និបាត ។

**សូមគោរពអញ្ជើញ !**